**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ :...៥០.១ ៧៨៣

រាជធានីភ្នំពេញ,ថ្ងៃទី..១៤...ខែ..កក្កដា..ឆ្នាំ២០០៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ជំរាបមក**

**លោក សំ បូរ ប្រធានសមាគមរថយន្តពេទ្យចល័តកុមារខ្មែរ-អាមេរិចកាំង**

__កម្មវត្ថុ__ : អំពីការសុំចុះបញ្ជីរបស់ ***សមាគមរថយន្តពេទ្យចល័តកុមារខ្មែរ-អាមេរិចកាំង*** នៅក្រសួងមហាផ្ទៃ ។

__យោង__ : លិខិតលេខ ***គ្មាន*** ចុះថ្ងៃទី***១១*** ខែ***មេសា*** ឆ្នាំ***២០០៨*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមរថយន្តពេទ្យចល័តកុមារខ្មែរ-អាមេរិចកាំង*** ។

តបតាមកម្មវត្ថុ និង យោងខាងលើ សូមជំរាបលោកប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី ***សមាគមរថយន្តពេទ្យចល័តកុមារខ្មែរ-អាមេរិចកាំង*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅផ្ទះលេខ***៩១៥*** ផ្លូវលេខ***៧១K*** ភូមិ***តាខ្ទួន*** សង្កាត់***កាកាប*** ខណ្ឌ***ដង្កោ*** ***រាជធានីភ្នំពេញ*** នោះហើយ ។ ***សមាគមរថយន្តពេទ្យចល័តកុមារខ្មែរ-អាមេរិចកាំង*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបំរើអោយគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមរថយន្តពេទ្យចល័តកុមារខ្មែរ-អាមេរិចកាំង ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាបជាព័ត៌មាន ។
សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ស ខេង**

__*ចម្លងជូន :*__
- ទីស្តីការគណៈរដ្ឋមន្ត្រី
" __ដើម្បីជូនជ្រាប__ "
- សាលាក្រុងភ្នំពេញ